## ព័ត៌មានទូទៅអំពីក្រុមប្រឹក្សាមូលនិធិ ស.អ.

**ក្រុមប្រឹក្សាមូលនិធិ ស.អ.** មានសមាសភាព៧រូប ដែលមានរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាប្រធាន, រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍០១រូប ជាអនុប្រធានទី០១, តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ០១រូប ជាអនុប្រធានទី០២, តំណាងក្រសួងអប់រំ យុវជន និងកីឡា០១រូប ជាសមាជិក, តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ០១រូប ជាសមាជិក, អគ្គនាយកនៃអគ្គនាយកដ្ឋាន បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន០១រូប ជាសមាជិកអចិន្ត្រៃយ៍ និងអគ្គនាយកនៃអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍០១រូប ជាសមាជិក។ **ក្រុមប្រឹក្សាមូលនិធិ ស.អ.** មានការប្រជុំប្រចាំត្រីមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំវិសាមញ្ញ តាមគំនិតផ្តួចផ្តើមរបស់ប្រធាន**ក្រុមប្រឹក្សាមូលនិធិ ស.អ.** ឬតាមការស្នើសុំពីសមាជិក **ក្រុមប្រឹក្សាមូលនិធិ ស.អ.** ចំនួន២/៣ (ពីរភាគបី)។

## ក្រុមប្រឹក្សាមូលនិធិ ស.អ. មានមុខងារ និងភារកិច្ចដូចតទៅ៖

១. គ្រប់គ្រង និងចាត់ចែងមូលនិធិ **ស.អ.**
២. ពិនិត្យ និងអនុម័តលើផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ
៣. លើកកម្ពស់ និងជំរុញការកសាងសមត្ថភាព ការស្រាវជ្រាវ និងការអភិវឌ្ឍ និងនវានុវត្តន៍ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព
៤. ពិនិត្យ និងអនុម័ត លើផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ និងនវានុវត្តន៍
៥. ពិនិត្យនិងអនុម័តលើផែនការ និងយន្តការប្រើប្រាស់មូលនិធិ **ស.អ.** និងយន្តការអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងអភិវឌ្ឍ និងនវានុវត្តន៍
៦. ពិនិត្យនិងអនុម័តលើគម្រោង អនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ និងនវានុវត្តន៍
៧. គ្រប់គ្រងសមិទ្ធផលដែលទទួលបានពីគម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ និងនវានុវត្តន៍
៨. តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសម្មភាពនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍនិងនវានុវត្តន៍
៩. រៀបចំរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍ជូនរដ្ឋាភិបាល
១០. ធ្វើជាតំណាងស្របច្បាប់ របស់មូលនិធិ **ស.អ.** ក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងស្ថាប័នរដ្ឋ ឬឯកជនដៃគូជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធផ្សេងទៀត
១១. ពិនិត្យនិងអនុម័តការផ្តល់ ការបន្ត ការផ្ទេរ ការផ្អាក ឬបញ្ឈប់គម្រោងអនុវត្តការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍
១២. ពិនិត្យនិងអនុម័តលើថវិកា រួមទាំងថវិកាសម្រាប់ចំណាយជូនរដ្ឋបាលប្រចាំឆ្នាំ និង
១៣. អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់មូលនិធិ **ស.អ.**។

គោលបំណងធំនៃការបង្កើតមូលនិធិ **ស.អ.** ឡើង គឺដើម្បីជំរុញការអភិវឌ្ឍធនធានមនុស្សផ្នែក បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ជំរុញការស្រាវជ្រាវ និងអភិវឌ្ឍ នវានុវត្តន៍ផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងជំរុញការបង្កើតអាជីវកម្មថ្មីៗ លើវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

**ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់អ៊ីម៉ែល** info@cbrd.gov.kh